ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១០......សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការពង្រីកដែនអំណាចគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ពង្រីកជម្រៅមណ្ឌលដីគោកនៃដែនអំណាចគយតាមបណ្ដោយព្រំដែនគោកនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីគយ ក្នុងភូមិសាស្ត្រ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ក្រុងប៉ៃលិន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តកំពត ខេត្តតាកែវ ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម និងខេត្តក្រចេះ រហូតដល់ ជម្រៅ ហុកសិប (៦០) គីឡូម៉ែត្រ គិតពីព្រំដែនគោកចូលមកក្នុងប្រទេស និងគិតពីឆ្នេរ សមុទ្រចូលមកក្នុងប្រទេស ។ ការសម្រេចពង្រីកជម្រៅមណ្ឌលដីគោកនៃវង់អំណាចគយនេះ មានសុពលភាព ពីរ (២) ឆ្នាំ គិតចាប់ពីពេលដែលប្រកាសនេះចូលជាធរមាន ។

**ប្រការ ២.-**

កំណត់វង់អំណាចគយរហូតដល់ បី ( ៣ ) គីឡូម៉ែត្រ ជុំវិញការិយាល័យគយ ដែលមិនស្ថិតក្នុងវង់អំណាចគយដូចមានចែងខាងលើ ។

**ប្រការ ៣.-**

នៅក្នុងវង់អំណាចគយ មន្ត្រីគយមានសិទ្ធិអំណាចស្របតាមបញ្ញត្តិនៃច្បាប់ស្ដីពីគយ ។ ក្នុងករណីដែលទំនិញត្រូវបានកំណត់ក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨ នៃច្បាប់ស្ដីពីគយ សិទ្ធិអំណាចរបស់មន្ត្រីគយត្រូវគ្របដណ្ដប់នៅទូទាំងដែនគយដូចដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ២ នៃច្បាប់ស្ដីពីគយ ។

**ប្រការ ៤.-**

ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញទាំងអស់ដែលមានទីតាំង ឬធ្វើអាជីវកម្មក្នុងមណ្ឌលដីគោកនៃវង់អំណាចគយ ដូចមានចែងក្នុងប្រការខាងលើត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ពាក់ព័ន្ធនឹងបែបបទនៃការដឹក ជញ្ជូន ការធ្វើចរាចរចែកចាយ ការសន្និធិ និងការប្រើប្រាស់ទំនិញនៅក្នុងមណ្ឌលនេះ ដោយរួមបញ្ចូលផងដែរនូវកាតព្វកិច្ចកាន់រក្សាបញ្ជីសន្និធិទំនិញ និងឯកសារពាក់ព័ន្ធនានា និងកាតព្វកិច្ចសុំលិខិតអនុញ្ញាតដឹកជញ្ជូននាពេលចរាចរទំនិញ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៦
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ